**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# សេចក្តីថ្លែងការរួមស្តីពីជំហររបស់តំណាងសហគមន៍ និងសម្ព័ន្ធទន្លេកម្ពុជា (RCC) ចំពោះកិច្ចប្រជុំពិគ្រោះយោបល់តាមនីតិវិធីជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀង (PNPCA) របស់គម្រោងសាងសង់ទំនប់វារីអគ្គិសនីដនសាហុង ប្រទេសឡាវ

សម្ព័ន្ធទន្លេកម្ពុជា (RCC) និងសហគមន៍តាមដងទន្លេមេគង្គ និងទន្លេសាបសូមសំដែងនូវការព្រួយបារម្ភទាក់ទងនឹងដំណើរការធ្វើសេចក្តីសម្រេចចិត្ត ចំពោះការសាងសង់ទំនប់វារីអគ្គិសនីដនសាហុង នៅភាគខាងត្បូងប្រទេសឡាវ។ ក្តីបារម្ភចម្បងរបស់យើងទាក់ទងនឹងការដាក់ស្នើនាពេលថ្មីៗ ដោយរដ្ឋាភិបាលប្រទេសឡាវអំពីទំនប់ដនសាហុងសម្រាប់ការពិគ្រោះយោបល់ទៅតាម**នីតិវិធីជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀង** (PNPCA)។ យើងមានការព្រួយបារម្ភថាដំណើការនៃការពិគ្រោះយោបល់តាមនីតិវិធី PNPCA នៃទំនប់ដនសាហុងមិនត្រឹមត្រូវតាមកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការដើម្បីការអភិវឌ្ឍប្រកបដោយនិរន្តរភាពនៃអាងទន្លេមេគង្គ ឆ្នាំ១៩៩៥ (MRC Agreement, 1995)។ ដំណើរការពិគ្រោះយោបល់ PNPCA ដែលនឹងធ្វើនៅខេត្តស្ទឹងត្រែងនៅពេលខាងមុខនេះអាចនឹងដើរតាមបទពិសោធន៍ទំនប់សាយ៉ាប៊ូរី ដែលបានបំផ្លិចបំផ្លាញ និងប៉ះពាល់ធ្ងន់ធ្ងរដល់ធនធានទន្លេមេគង្គ និងប្រជាជន។

ការសិក្សាជាច្រើនបានបង្ហាញថា ប្រសិនបើទំនប់ដនសាហុងត្រូវបានសាងសង់នោះវានឹងមានផលប៉ះពាល់ធ្ងន់ធ្ងរដល់សត្វផ្សោត ត្រីទន្លេមេគង្គ និងការបម្លាស់ទីរបស់ត្រីនៅទូទាំងអាងទន្លេមេគង្គក្រោម និងទន្លេសាប ដែលគំរាមកំហែងដល់សន្តិសុខស្បៀង និងការចិញ្ចឹមជីវិតរបស់ប្រជាជនរាប់លាននាក់ ក៏ដូចជាស្ថេរភាពសេដ្ឋកិច្ច និងនយោបាយក្នុងតំបន់។ ទោះជាដូច្នេះក្តីគម្រោងសាងសង់ទំនប់ដនសាហុង នៅតែបន្តដំណើរការដដែល។

ការពិគ្រោះយោបល់ PNPCA គ្រាន់តែជាមធ្យោបាយដើម្បីផ្តល់ភាពស្របច្បាប់ដល់ការសាងសង់ទំនប់វារីអគ្គិសនីដនសាហុងតាមកិច្ចព្រមព្រៀងគណៈកម្មការទន្លេមេគង្គឆ្នាំ ១៩៩៥ ដោយសារះ

- មិនមានការផ្សព្វផ្សាយព័ត៌មានពីគម្រោងទំនប់ជាសាធារណៈជាភាសាជាតិ។
- មិនមានការពិគ្រោះយោបល់ជាសាធារណៈ ជាមួយភាគីពាក់ព័ន្ធជាមុន។
- មិនមានការព្រមព្រៀងលើលក្ខណៈវិនិច្ឆ័យរបស់នីតិវិធី ជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀង PNPCA។
- មិនមានការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផលប៉ះពាល់ឆ្លងដែន។
- មិនមានការព្រមព្រៀងលើគម្រោងសាងសង់ទំនប់ក្នុងចំណោមប្រទេសជាសមាជិក។
- មិនបានអញ្ជើញសហគមន៍តាមដងទន្លេមេគង្គឲ្យចូលរួមពេញលេញក្នុងដំណើរគម្រោង។

▪ មិនមានការឆ្លើយតបជាសាធារណៈ និងដោះស្រាយដោយតម្លាភាពពីកង្វល់របស់សហគមន៍

ក្នុងនាមសហគមន៍ និងសម្ព័ន្ធទន្លេកម្ពុជា (RCC) សូមស្នើដល់គណៈកម្មការទន្លេមេគង្គ និងរដ្ឋាភិបាលជាសមាជិកដូចខាងក្រោម៖

- បញ្ឈប់ការសាងសង់ទំនប់ដនសាហុង
- ធ្វើការសិក្សាពីហេតុប៉ះពាល់បរិស្ថាន និងផលប៉ះពាល់ឆ្លងដែន
- សិក្សាពីផលប៉ះពាល់លើធនធានជលផលទន្លេមេគង្គ
- ផ្សព្វផ្សាយព័ត៌មានពីគម្រោងទំនប់ជាសាធារណៈជាភាសាជាតិ។
- បើកឲ្យមានការពិគ្រោះយោបល់ពេញលេញជាសាធារណៈ ជាមួយភាគីពាក់ព័ន្ធជាមុន។
- គណៈកម្មការទន្លេមេគង្គ និងរដ្ឋាភិបាលជាសមាជិកត្រូវកំណត់ និងឯកភាពលើលក្ខណៈវិនិច្ឆ័យនៃដំណើរការតាមនីតិវិធី ជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀង (PNPCA)មុនចាប់ផ្តើមពិគ្រោះយោបល់។
- ប្រទេសក្នុងតំបន់ទន្លេមេគង្គក្រោមគោរពតាមកិច្ចព្រមព្រៀងគណៈកម្មការទន្លេមេគង្គឆ្នាំ ១៩៩៥

ធ្វើនៅស្ទឹងត្រែង ថ្ងៃទី១៦ ខែតុលា ឆ្នាំ ២០១៤

<u>បញ្ជីឈ្មោះអង្គការសមាជិកសម្ព័ន្ធទន្លេកម្ពុជា និងសហគមន៍ដែលគាំទ្រសេចក្តីថ្លែងការណ៍</u>

- វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (NGOF)
- បណ្តាញការពារទន្លេសេសាន សេកុង និងស្រែពក (3SPN)
- សម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល (FACT)
- សមាគមថែក្សាបរិស្ថាន និងវប្បធម៌ (CEPA)
- អង្គការភូមិខ្ញុំ (MVi)
- អង្គការស្ម័គ្រចិត្តដើម្បីសង្គម (CVS)
- អង្គការសង្គ្រោះអ្នកងាយរងគ្រោះកម្ពុជា (SVC)
- អង្គការអភិវឌ្ឍន៍សេដ្ឋកិច្ចសហគមន៍ (CED)
- សមាគមកសិករខ្មែរ (KFA)
- អង្គការអភិវឌ្ឍន៍ជនបទភាគឥសាន្ត (NRD)
- អង្គការពន្លកខ្មែរ (PLK )
- មជ្ឈមណ្ឌលម្លប់ព្រហ្មវិហារធម៌ (MPC )
- អង្គការសហប្រតិបត្តិការបរិស្ថាន និងទេសចរណ៍ (CETO)
- ក្រុមអភិវឌ្ឍន៍ជនបទកម្ពុជា (CRDT )
- អង្គការជំនួយអភិវឌ្ឍន៍ និងសន្តិភាព ( PDAO)

- អង្គការសកម្មភាពសង្គម ដើម្បីផ្លាស់ប្តូរលើផ្នែកអប់រំ និងអភិវឌ្ឍន៍ជនបទ(SACRET)
- សម្ព័ន្ធប្រជានេសាទកម្ពុជា ( CCF)
- លោក គង់ ចាន់ធី សហគមន៍ទន្លេមេគង្គខេត្តស្ទឹងត្រែង ០១២៥០៩៨៧៩
- លោក ហ៊ួត សេង សហគមន៍ទន្លេមេគង្គខេត្តស្ទឹងត្រែង
- លោក អាន ហ៊ួ សហគមន៍ទន្លេមេគង្គខេត្តក្រចេះ ០៩៧២៩១៧៩៥០
- លោកស្រី សែម វន សហគមន៍ទន្លេមេគង្គខេត្តក្រចេះ
- លោក អ៊ា អ៊ាងណាំ សហគមន៍ទន្លេមេគង្គខេត្តកំពង់ចាម ០៨៩ ៩៩៩ ២៥០
- លោក ហេង អ៊ុយ សហគមន៍ទន្លេមេគង្គខេត្ត ព្រៃវែង ០១២ ២៨៣ ៨១៨
- លោក មិនម៉ុន សហគមន៍វាលទំនាបកណ្តាលខេត្តកណ្តាល ០៨៨ ៨៧២ ៧៨៩
- លោក ឡុង សូថៃត សហគមន៍ទន្លេសាប ០១២៩៨៩៣១៨


**<u>អាសយដ្ឋានទំនាក់ទំនង៖</u>**

ការិយាល័យវេទិការនៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា

ផ្ទះលេខ៩-១១ ផ្លូវ៤៧៦ ទួលទំពូង ភ្នំពេញ

ទូរស័ព្ទលេខ៖ (៨៥៥) ២៣ ២១៤ ៤២៩/ ១២ ៧៩៣ ៤៨៩

អ៊ីម៉ែល៖ vannara@ngoforum.org.kh / ngoforum@ngoforum.org.kh

**Contact Address:**
The NGO FORUM on Cambodia Office.
#9-11, St. 476, Sangkat Toul Tompoung1, P.O. Bo 2295 Phnom Penh 3
Tel: (855) 23 214 429 Ext. No 106, Fax: (855) 23 994 063
Mobile: (855) 12 793 489, Email: vannara@ngoforum.org.kh, Skype: tekvannara1
Web: ngoforum.org.kh | ***Working Together for Positive Change***